## ៥. លក្ខណៈពិសេសរបស់សត្វផ្សោតទន្លេមេគង្គ




ដងខ្លួនមានប្រវែង ២.៧៥ម នៅពេលដែលវាមានអាយុ ២៦ឆ្នាំ

សត្វផ្សោត ជាថនិកសត្វដែលមានលក្ខណៈពិសេសជាងពពួកសត្វដទៃទៀត ព្រោះខ្លួនរបស់វាអាចប្រែប្រួលពណ៌សម្បុររបស់ទៅតាមទឹកទន្លេ (នៅរដូវទឹកឡើង គឺមានពណ៌សនិងនៅរដូវទឹកសំរក គឺមាន ពណ៌ប្រផេះ) ហើយយើងមិនអាចធ្វើការកំណត់ពណ៌របស់វាអោយប្រាកដកច្បាស់លាស់នោះទេ គឺវាប្រែប្រួលពណ៌រហូត។ លក្ខណៈពិសេសម៉្យាងទៀត គឺសត្វផ្សោតទន្លេមេគង្គនេះក្នុងខ្លួនរបស់វាបែងចែកខួរក្បាលជា ២ថត សំរាប់ធ្វើការផ្លាស់ប្តូរចលនានៅពេលដែលវាសំរាក (ដេក) គឺម្ខាងធ្វើចលនា និងម្ខាងទៀតសំរាកតែវាផ្លាស់ប្តូរចលនាគ្នាជានិច្ច មិនថាយប់ឬថ្ងៃឡើយ (យោងតាមការស្រាវជ្រាវរបស់ក្រុមអ្នកវិទ្យាសាស្រ្ត)។

ចំណែកឯភាពវៃឆ្លាតរបស់សត្វផ្សោតក្បាលត្រឡោកនេះក៏មិនចាញ់សត្វផ្សោតសមុទ្រដែរ ដោយយោងតាមការស្រាវជ្រាវរបស់អ្នកអភិរក្សសត្វនៅប្រទេសជប៉ុន បានយកសត្វផ្សោតក្បាលត្រឡោកទន្លេមេគង្គនេះចំនួន ២ក្បាលទៅបង្ហាត់ជាមួយសត្វផ្សោតសមុទ្រលទ្ធផល គឺសត្វផ្សោតក្បាលត្រឡោកនេះអាចបង្ហាត់បានដូចគ្នាទៅនឹងសត្វផ្សោតសមុទ្រដែរ ហើយភាពវៃឆ្លាតរបស់វាគឺដូចគ្នា។

## ៦. ភាពខុសគ្នារវាងសត្វផ្សោត និង ត្រី

មានការយល់ច្រលំពីសំណាក់ប្រជាជនយើងមួយចំនួនដែលបានគិតថាសត្វផ្សោត គឺជាប្រភេទត្រីដ៏ធំមួយ ។ សត្វផ្សោតទន្លេមេគង្គ (Irawaddy dolphin) មិនមែនជាប្រភេទត្រីទេ ហើយវាក៏ត្រូវការខ្យល់សំរាប់ដកដង្ហើម ដូចជាមនុស្ស និងពពួកសត្វចតុបាតដទៃទៀតដែរ ។

សត្វផ្សោត និង ត្រី មានលក្ខណៈខុសគ្នាដូចជាៈ

| **សត្វផ្សោត** | **ត្រី** |
|---|---|
| មានព្រុយនៅលើមុខរបស់ពួកវា | មិនមានព្រុយលើមុខទេ-មានតែស្រកានៅដងខ្លួនរបស់វា |
| ខ្លួនរបស់វាមានកំដៅ និង មានឈាម | ខ្លួនរបស់វាត្រជាក់ និង មានឈាម |
| សត្វផ្សោតផ្តល់កំនើតអោយកូនរបស់វា ដូចជាកូនមនុស្សដែរ （ពេលកើតគឺចេញកន្ទុយមកមុន） ហើយចិញ្ចឹមកូនដោយទឹកដោះ | ត្រីផ្តល់កំណើតអោយកូនរបស់វាជាពង ហើយចិញ្ចឹមកូនដោយស៊ីរុក្ខជាតិ និង សត្វល្អិតតូចៗ |
| កូនរបស់សត្វផ្សោតមិនអាចរស់នៅដោយគ្មានមេរបស់វាទេ ក្នុងរយៈពេលយ៉ាងហោចណាស់ក៏មួយឆ្នាំដែរ | កូនត្រីអាចរស់នៅដោយខ្លួនឯងបាន និងមិនចាំបាច់មានមេថែរក្សាឡើយ |
| មានសួត សំរាប់ធ្វើការដកដង្ហើមតាមប្រហោងស្រកី | វាមិនត្រូវការងើបដកដង្ហើមយកខ្យល់ទេ ប៉ុន្តែវាត្រូវការអុកស៊ីសែនពីក្នុងទឹក |
| កន្ទុយរបស់វារាងផ្តេក ហើយធ្វើចលនាបកចុះ-ឡើង | កន្ទុយរបស់វារាងបញ្ឈរ ហើយធ្វើចលនាបកឆ្វេង-ស្តាំ |

## ៧. ការស្លាប់របស់សត្វផ្សោតទន្លេមេគង្គ



អត្រានៃការស្លាប់របស់សត្វផ្សោតបណ្តាលមកពីកត្តាពីរយ៉ាង គឺកត្តាមនុស្ស និងកត្តាធម្មជាតិៈ

**កត្តាមនុស្ស**

- ការដាក់មងត្រី
- ការបំពុលត្រី
- ការបោកគ្រាប់បែក
- ភាពកើនឡើងនៃចំនួនទេសចរនៅក្នុងតំបន់ធ្វើអោយមានការប៉ះពាល់ដល់ការរស់នៅរស់សត្វផ្សោត ដូចជាៈ កាលណាមានទេសចរចុះទៅទស្សនាច្រើន (ការជិះទូកទស្សនាសត្វផ្សោត) ធ្វើអោយសត្វផ្សោតពិបាកក្នុងការស្វែងរកចំណី (ត្រី) ព្រោះតែការគេចវេសចេញហ្វូងមនុស្សដែលតាមទស្សនា។ ទេសចរចូលទៅទស្សនាច្រើនធ្វើអោយមានការប៉ះពាល់ទាំងបរិស្ថាន និងជីវិតរបស់សត្វផ្សោតផងដែរដោយការចោលសំរាមឬកាកសំណលនានាចូលទៅក្នុងទឹកដែលធ្វើអោយមានជាតិពុល និងកខ្វក់ ទឹកផងដែរ។

**កត្តាធម្មជាតិ**

ការស្លាប់របស់សត្វផ្សោតដោយកត្តាធម្មជាតិនេះ គឺមានតិចតួចណាស់ដូចជាៈ

- ដោយគ្រោះទឹកជំនន់ ឬក៏គ្រោះរាំងស្ងួត
- ដោយសារកត្តាអាកាសធាតុ
- ដោយអាយុរបស់វាចាស់ ឬឈឺ

ដូចដែលបានធ្វើការរៀបរាប់ទាំងពីរកត្តាដូចខាងលើ យើងអាចធ្វើការប៉ាន់ស្មានដឹងថា មនុស្សជាកត្តាដែលធ្វើអោយមានផលប៉ះពាល់ខ្លាំងបំផុត ចំពោះភាពបាត់បង់របស់សត្វផ្សោត។

## ៨. ការអភិរក្សសត្វផ្សោតទន្លេមេគង្គ

ដោយសារសត្វផ្សោតទន្លេមេគង្គជាថនិកសត្វដ៏កំរ និងមានតិចតួចបំផុតហើយទទួលរងនូវការយាយីជីវិតពីមនុស្ស ដែលជាហេតុធ្វើអោយមានអត្រាថយចុះជាលំដាប់នៃចំនួនពពួកថនិកសត្វដ៏កំរនេះ ហើយក៏អាចឈានទៅដល់ការដាច់ពូជនៃ សត្វផ្សោតទឹកសាបនេះពីលើផែនដីនេះទៀតផង ហេតុនេះហើយទើបបណ្តាលអោយមានការបង្កើតនូវក្រុមអ្នកអភិរក្សសត្វផ្សោតទន្លេមេគង្គនេះឡើង ។

គោលបំណងនៃការបង្កើតក្រុមអ្នកអភិរក្សនេះឡើង គឺដើម្បីធ្វើការការពារកុំអោយផុតពូជ និងថែរក្សាសត្វផ្សោតប្រភេទទឹកសាបនេះអោយមាននៅលើផែនដីយើងដើម្បីអោយក្មេងៗជំនាន់ក្រោយបានស្គាល់ពីថនិកសត្វប្រភេទនេះ ។

បច្ចុប្បន្ននេះ បន្ទាប់ពីក្រុមអ្នកអភិរក្សសត្វផ្សោតរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏មានការជួយឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាលឈ្មោះ **Mekong Dolphin Consevation Project (MDCP)** ហើយក៏មានការចូលរួមផងដែរពីសំណាក់អង្គការអភិរក្សសត្វព្រៃ ឈ្មោះ **WWF** ។

គោលបំណងរបស់ពួកគេដែលចូលរួមសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីទប់ស្កាត់អត្រានៃការបាត់បង់របស់សត្វផ្សោតទន្លេមេគង្គនេះដោយធ្វើការពន្យល់ណែនាំពីផលអាក្រក់ និងអត្ថប្រយោជន៍របស់សត្វផ្សោតទៅដល់ប្រជាជនដែលរស់នៅក្នុងតំបន់អោយមានការយល់ដឹងកាន់តែច្រើនឡើង ។



ពីមុនប្រជាជនដែលរស់នៅក្នុងតំបន់នេះមិនមានការយល់ខ្ពស់ពីផលអាក្រក់ និងអត្ថប្រយោជន៏របស់សត្វផ្សោតនេះទេ ហើយថែមទាំងមានការខឹងចំពោះការចេញច្បាប់បំរាមរបស់រាជរដ្ឋាភិបាលទៀតផង ប៉ុន្តែក្រោយពីមានការចុះទៅពន្យល់ណែនាំប្រជាពលរដ្ឋទាំងនោះដល់មូលដ្ឋាន ទើបធ្វើអោយពួកគេមានការបានយល់កាន់តែច្បាស់ហើយថែមទាំងធ្វើការចូលរួមការពារជាមួយរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក្នុងការទប់ស្កាត់ការសំលាប់សត្វផ្សោតនេះទៀតផង ។ មិនត្រឹមតែមានការបំរាមមិនអោយមានការប្រើប្រាស់មងដាក់ត្រីគ្រប់ប្រភេទការបំពុលត្រី និងការបោកគ្រាប់បែកនោះទេ ហើយថែមទាំងបង្កើតអោយមានក្រុមឆ្មាំទន្លេទៀតផង (៥-៦ប៉ុស្តិ៍នៅតាមតំបន់អន្លង់នានាដែលស្ថិតនៅតាមដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា) ។